# ពិធីបុណ្យបញ្ចុះសីមា
# ព្រះវិហារវត្តមុនីប្រសិទ្ធិវង្ស
## ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្ដាល

បណ្ណាល័យ LIBRARY BUDDHIST INSTITUTE



• ផ្ដើមស្ថាបនា : ខែមាឃ ឆ្នាំវក ចត្វាស័ក ព.ស ២៥៣៦
ត្រូវនឹងថ្ងៃទី ៦ កុម្ភៈ គ.ស ១៩៩៣

• បញ្ចុះសីមា : ខែមាឃ ឆ្នាំច ឆស័ក ព.ស ២៥៣៨
ត្រូវនឹងថ្ងៃទី ២៣ កុម្ភៈ គ.ស ១៩៩៥

២១៤.
២

www.budinst.gov.kh www.elibraryofcambodia.org

# ស្នាដៃនេះ

កើតឡើងពីកិច្ចសហការគ្នា រវាង

**ពុទ្ធសាសនបណ្ឌិត្យ** និង **បណ្ណាល័យអេឡិចត្រូនិចខ្មែរ**

ក្នុងគោលបំណងយ៉ាងមុតមាំដើម្បីថែរក្សា ការពារ កុំឲ្យបាត់បង់តទៅទៀត

ព្រមទាំងផ្សព្វផ្សាយស្នាដៃ-ឯកសារទាំងនេះ

សម្រាប់សាធារណជនប្រើប្រាស់ដោយមិនគិតកម្រៃ។

សូមថ្លែងអំណរគុណដល់

**អង្គការរីស្សូ កូស៊ី-កៃ  វិទ្យាស្ថានបើកទូលាយ**

**ករុណាខ្មែរ និង មូលនិធិខ្មែរសម្រាប់ការសិក្សា**

ដែលបានគាំទ្រគម្រោងការស្នាដៃនេះ សម្រាប់ទុកក្នុងបណ្ណាល័យអេឡិចត្រូនិច។

Buddhist Institute of Ministry of Cult and Religion and eLibrary of Cambodia have made a cooperative effort to digitalize books and manuscripts in order to preserve our Cambodian literary heritage. This will promote and provide easy, instant access, free of charge to the public and future generations to come.

A sincere thank you to our generous supporters: Rissho Kosei-Kai, Open Institute, Karuna Cambodia and Cambodian Education Excellence Foundation, who made this endeavor possible.

www.budinst.gov.kh www.elibraryofcambodia.org

ប ១៤.២

វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត
បណ្ណាល័យ
LIBRARY
BUDDHIST INSTITUTE

ព្រះករុណាព្រះបាទសម្តេច
ព្រះនរោត្តម សីហនុ វរ្ម័ន
ព្រះមហាក្សត្រ នៃ ព្រះរាជាណាចក្រកម្ពុជា

សូមក្រាបថ្វាយបង្គំ ព្រះអង្គចៅអធិការវត្ត មុនីប្រសិទ្ធិចង្វា ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល

ព្រះអង្គចៅអធិការជាទីគោរពសក្ការៈ

ខ្ញុំព្រះករុណា បានទទួលរួចហើយនូវព្រះសារលិខិត ចុះថ្ងៃទី ៦ ខែ មករា ឆ្នាំ ១៩៩៥ របស់ព្រះអង្គដែលស្តីអំពីការសុំ ខ្ញុំព្រះករុណា ទៅជាអធិបតីសម្ពោធកាត់ខ្សែត្រីសីមា ព្រះវិហារថ្មីនៃវត្ត មុនីប្រសិទ្ធិចង្វា ។

ខ្ញុំព្រះករុណា សូមថ្លែងនូវអំណរព្រះគុណដ៏ជ្រាលជ្រៅ ប្រគេនព្រះអង្គ និង សូមទទួលការស្នើសុំនេះ ដោយបិតិសោមនស្សរីករាយជាអតិបរមា ។

ខ្ញុំព្រះករុណា សូមប្រសិទ្ធិពរដ៏បវរសួស្តី ប្រគេនព្រះអង្គឱ្យបានទទួលនូវពុទ្ធពរទាំងប្រាំប្រការគឺ អាយុ វណ្ណ សុខ ពល និងបដិភាណកុំបីឃ្លៀងឃ្លាតឡើយ ។

សូមព្រះអង្គ ព្រះមេត្តាទទួលនូវសេចក្តីគោរពសក្ការៈ ស្រឡាញ់ដ៏ជ្រាលជ្រៅ អំពីខ្ញុំព្រះករុណា ។

នរោត្តម សីហនុ

រាជធានីភ្នំពេញ, ថ្ងៃទី ៩ ខែ មករា ឆ្នាំ ១៩៩៥

www.budinst.gov.kh www.elibraryofcambodia.org



ព្រះរមណីយត្ថេរោ **ម្លូខ រ៉ាវ** ចៅអធិការ
វត្តមុនីប្រសិទ្ធីវង្ស, និងជាព្រះសមុហ៍អនុគណ
ស្រុកពញាឮ ខេត្តកណ្តាល

www.budinst.gov.kh www.elibraryofcambodia.org

២៦០
២៦៣

# កម្មវិធីបុណ្យ

# បញ្ចុះសីមាព្រះវិហារ

# វត្តមុនីប្រសិទ្ធិវង្ស

ឃុំព្រែកឈ្មោះ ស្រុកពញាឮ ខេត្តកណ្ដាល

•••

ថ្ងៃ ៨រោច-៩រោច-១០រោច-១១រោច
ខែមាឃ ព.ស ២៥៣៨
ត្រូវនឹងថ្ងៃទី ២៣-២៤-២៥-២៦
ខែកុម្ភៈ គ.ស ១៩៩៥

បណ្ណាល័យ
វិទ្យាស្ថានពុទ្ធសាសនបណ្ឌិត
LIBRARY
BUDDHIST INSTITUTE
៥៧៤/៩៥
16-8

www.budinst.gov.kh www.elibraryofcambodia.org

## ពិធីបុណ្យបញ្ចុះសីមា
## ព្រះវិហារ វត្តមុនីប្រសិទ្ធិវង្ស

ក្រោមព្រះបរមរាជាធិបតីភាព

ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន**

ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា

---

## សេចក្តីនិមន្តន៍ យាង អញ្ជើញ

អាត្មាភាព ចៅអធិការ និងគណៈកម្មការ អាចារ្យវត្ត ព្រមទាំងពុទ្ធបរិស័ទជើងវត្ត **មុនីប្រសិទ្ធិវង្ស** នៅឃុំព្រែកព្នៅ និងនៅរាជធានីភ្នំពេញ បានមូលមតិគ្នាជាឯកច្ឆ័ន្ទ ប្រារព្ធធ្វើពិធីបុណ្យបញ្ចុះសីមាព្រះវិហារថ្មី ដែលទើបនឹងបានកសាងហើយជាស្ថាពរ ដើម្បីប្រតិស្ឋានទុកជាសម្បត្តិជាតិ និង សម្បត្តិព្រះពុទ្ធសាសនា ក្នុងវត្តមុនីប្រសិទ្ធិវង្ស ឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្តាល តទៅ ។

នៅក្នុងពិធីដ៏មហោឡារិកនេះ អាត្មាភាព ខ្ញុំព្រះករុណា យើងខ្ញុំសូមនិមន្តព្រះថេរានុត្ថេរៈគ្រប់ព្រះអង្គ សូមយាងព្រះអង្គម្ចាស់ និងសូមអញ្ជើញ ឯកឧត្តម លោកជំទាវ លោក លោកស្រី ពុទ្ធបរិស័ទជិតឆ្ងាយចូលរួមអនុមោទនា និង ចាប់មគ្គផលបំពេញកុសល តាមកម្លាំងសទ្ធាជ្រះថ្លារៀង១ខ្លួន កុំបីខាន ដូចមានកម្មវិធីបុណ្យ តទៅនេះ ៖

www.budinst.gov.kh www.elibraryofcambodia.org

# កម្មវិធីបុណ្យ

## ថ្ងៃទីមួយ

ថ្ងៃ ព្រហស្បតិ៍ ៨ រោច ខែមាឃ
ត្រូវនឹងថ្ងៃទី ២៣ កុម្ភៈ ឆ្នាំ១៩៩៥

- ពេលព្រឹក ៖

ម៉ោង ៧:០០ ៖ - ប្រគេនយាគូព្រះសង្ឃ,

ម៉ោង ៨:៣០ ៖ - ជួបជុំពុទ្ធបរិស័ទជិតឆ្ងាយធ្វើពិធីក្រុងពាលី

ម៉ោង ១១:០០ ៖ - ប្រគេនចង្ហាន់ព្រះសង្ឃ,

- ពេលរសៀល ៖

ម៉ោង ២:០០ ៖ - ពិធីដង្ហែជុំថ្មនិមិត្តសីមា,

៖ - ពិធីចំរើនព្រះបរិត្ត,

៖ - ពិធីវេរជុំថ្មនិមិត្តសីមា, ព្រះសង្ឃ ស្វាធ្យាយជយន្តោ ,

៖ - ធម្មទេសនាអំពីសីមាកម្ម សំដែងដោយ ព្រះវិមលវេទី ឡុង យុង មេគណខេត្ត កណ្តាល,

www.budinst.gov.kh www.elibraryofcambodia.org

• ពេលយប់ ៖

ម៉ោង៨៖៣០ ៖ - និមន្តព្រះសង្ឃចំរើនព្រះបរិត្តក្នុងព្រះវិហារថ្មី, ធ្វើពិធីបញ្ឆន់តារាងនិងបញ្ចុះមហាសីមា

* * *

## ថ្ងៃទីពីរ

ថ្ងៃ សុក្រ ៩ រោច ខែមាឃ

ត្រូវនឹងថ្ងៃទី ២៤ កុម្ភៈ ឆ្នាំ ១៩៩៥

• ពេលព្រឹក

ម៉ោង ៦៖៣០ ៖ - ប្រគេនយាគូព្រះសង្ឃ,

ម៉ោង ៧៖០០ ៖ - ជួបជុំព្រះសង្ឃ ពុទ្ធបរិស័ទ មន្ត្រីរាជការ អ្នកមុខ អ្នកការ រង់ចាំទទួលស្វាគមន៍ព្រះរាជដំណើរយាងមកដល់ របស់ព្រះករុណាព្រះបាទសម្តេច ព្រះនរោត្តម សីហនុ វរ្ម័ន ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហេសី

ម៉ោង ៨៖០០ ៖ - ភ្ញៀវកិត្តិយសជាតិ និង អន្តរជាតិ អញ្ជើញដល់,

www.budinst.gov.kh www.elibraryofcambodia.org

ម៉ោង ៨:៣០ : - ព្រះករុណាជាអម្ចាស់ជីវិតលើត្បូង និង សម្តេចព្រះមហេសី យាងដល់វត្ត មុនី-ប្រសិទ្ធិវង្ស,

- កងកិត្តិយស ត្រែទ័ព ថ្វាយវន្ទនកិច្ច,
- ព្រះសង្ឃស្វាធ្យាយជយន្តោ ថ្វាយព្រះពរ,
- ស្លូត្របទសរភញ្ញ ថ្វាយ,
- សុន្ទរកថាស្វាគមន៍របស់គណៈកម្មការវត្ត,
- ព្រះសង្កថា របស់ព្រះករុណា ជាអម្ចាស់ជីវិតលើត្បូង,
- ពិធីកាត់ខ្សែគ្រឹះសីមាព្រះវិហារថ្មី,

ម៉ោង ១០:៤៥ : - ពិធីជូនព្រះរាជដំណើរយាងនិវត្តន៍,

ម៉ោង ១១:០០ : - ប្រគេនចង្ហាន់ព្រះសង្ឃ,

- ពេលល្ងាច :

ម៉ោង ៥:០០ : - និមន្តព្រះសង្ឃចំរើនព្រះបរិត្ត,

ម៉ោង ៦:០០ : - សំដែងធម្មទេសនា អំពីព្រះធម្មគោរព ដោយសម្តេចព្រះមហាសុមេធាធិបតី **នេព ខង្ស** ព្រះសង្ឃរាជ គណៈមហា-និកាយ,

ម៉ោង ៨:៣០ : - ពិធីសំដែងសិល្បៈកំសាន្ត,

* * *

www.budinst.gov.kh www.elibraryofcambodia.org

# ថ្ងៃពិធី

ថ្ងៃ សៅរ៍ ១០ រោច ខែមាឃ
ត្រូវនឹងថ្ងៃទី ២៥ ខែកុម្ភៈ ឆ្នាំ ១៩៩៥

• ពេលព្រឹក ៖

ម៉ោង ៧៖០០ ៖ - ប្រគេនយាគូព្រះសង្ឃ,

ម៉ោង ១១៖០០ ៖ - ប្រគេនចង្ហាន់ព្រះសង្ឃ,

• ពេលល្ងាច

ម៉ោង ៥៖០០ ៖ - និមន្តព្រះសង្ឃចំរើនព្រះបរិត្ត,

ម៉ោង ៦៖០០ ៖ - សំដែងធម្មទេសនាព្រះធម្មព្រាស់ ដោយព្រះតេជព្រះគុណចិត្តបាលោ ជា សំអាង ចៅអធិការវត្តសុវណ្ណារ៉ាំ,

• ពេលយប់ ៖

ម៉ោង ៨៖៣០ ៖ - ពិធីសំដែងសិល្បៈជូនកំសាន្ត,

ម៉ោង ៤ ទៀបភ្លឺ ៖ - ពិធីពុទ្ធាភិសេក,

* * *

www.budinst.gov.kh www.elibraryofcambodia.org

## ថ្ងៃទីបួន

ថ្ងៃ អាទិត្យ ១១ រោច ខែមាឃ

ត្រូវនឹងថ្ងៃទី ២៦ កុម្ភៈ ឆ្នាំ ១៩៩៥

- ពេលព្រឹក ៖

ម៉ោង ៧:០០ ៖ - ប្រគេនយាគូព្រះសង្ឃ,

ម៉ោង ៨:០០ ៖ - និមន្តព្រះសង្ឃ ២០៩ អង្គទ្រង់បិណ្ឌបាត

ម៉ោង ១:៣០ ៖ - សំដែងធម្មទេសនាគ្រែបី, ពហូ ទេវា... ឆ្លង និងបញ្ចប់ពិធីបុណ្យ ។

ចប់កម្មវិធីបុណ្យ

●●●

www.budinst.gov.kh www.elibraryofcambodia.org

# អ្នកផ្តួចផ្តើមកាន់ទិស
# ក្នុងពិធីបុណ្យបញ្ចុះខណ្ឌសីមា
# ព្រះវិហារវត្តមុនីប្របសិទ្ធិវង្ស

១. **ឧត្តរទិស** (សីមាឥន្ទ្រកីល)

ឯកឧត្តម ទៀ បាញ់ និងលោកជំទាវ ពៅ ធឿន
ឯកឧត្តម ទា ចំរ៉ាត
លោក ណើម សុវត្ថិ និងអ្នកស្រី ម៉ត់ សុគន្ធ
លោក ឡេង ទូច អ្នកស្រី លី សុខា
លោក ប្រាក់ ម៉ារឌី
លោក មុំ សុភាព
លោក ផា សុខែម
លោក ជួន សុត
លោក ភួង ភិរម្យ
លោក ប៉ាង ធារ៉ូ

២. **ទិសបូពា** (ភូមិកណ្តាល)

លោក ម៉ក់ លី
លោក ចាន់ ប៊ុនហុង
លោក អ៊ូច ឈន

www.budinst.gov.kh www.elibraryofcambodia.org

៣. **ទិសអាគ្នេយ៍** (ភូមិផ្សារលិច)

លោក ឃួន ថុល

លោក ឡុង ហួន

លោក ហៀង ឡេង

៤. **ទិសឧត្តរិណា** (បឹងកេងកង)

លោក សួន ភិរម្យ និងអ្នកស្រី ថោង ហៀង ព្រមទាំងបុត្រ

លោក យាយ សៀម ណាយ ព្រមទាំងបុត្រ

អ្នកស្រី សឿ ចាន់ថា

អ្នកស្រី រស់ សេរី និង មាតាបិតា

លោក ភួង ប៊ុនធឿន និង ភរិយា

៥. **ទិសនិរតី** (ភ្នំពេញ)

លោក ឱ សុខា

លោក ឡូយ សុផាត

លោក គ្រួយ សៀងលាង

៦. **ទិសបស្ចិម** (បឹងកេងកង)

លោក បាន វណ្ណី អ្នកស្រី ម៉ៅ សាយគីម

លោក អ៊ុក ម៉ានី អ្នកស្រី ៣ សៀងឡេង

លោក អ៊ុត ឱរ៉ាល់ អ្នកស្រី លឹម សៀកងីម

លោក ម៉ៅ វុឌ្ឍី អ្នកស្រី លឹម សំបូរ

www.budinst.gov.kh www.elibraryofcambodia.org

លោក ហែម សារ៉ន អ្នកស្រី ហែម ចំរើន

លោក គុជ សារឿន អ្នកស្រី លឹម លីឡេង

លោក អាន សំអុល អ្នកស្រី ហ៊ូ ឡុង

លោក កែវ ហ៊ូ អ្នកស្រី ម៉ម អ៊ី

៧. **ទិសពាយ័ព្យ** (ភូមិពោធិមណ្ឌល)

លោក ពេជ ណុំ

លោក ម៉ាត់ សារឿន

លោក ញ៉ឹក អឿន

លោក ព្រំ វង្ស អ្នកស្រី អ៊ុក ប៊ុនរឿន

៨. **ទិសឧត្តរ** (ភូមិព្រៃកញ្ចៅ)

លោក តេង ឆាយ

លោក ម៉ៃ សយ

ឧបាសក តាន់ ណាង

ឧបាសក ប៊ុច ឆឹងហាយ

៩. **ទិសព្ធសាន** (ផ្សារតូច)

លោក ឡោ ជាវ អ្នកស្រី ឈឺវ វ៉ារី

ឧបាសិកា អៀង ជូ ព្រមទាំងបុត្រ

លោក ប៊ុន ចាន់ធូ

លោក ម៉ៅ ឌីណា

www.budinst.gov.kh www.elibraryofcambodia.org

ឯកឧត្តម ដោក ណារិន និងលោកជំទាវ
លោកស្រី មុនី សុង
លោក អ៊ិ សារិទ្ធិ និងអ្នកស្រី
ឧបាសក តាន់ ពាង និងអ្នកស្រី
លោក ហូ ស្រេង និងអ្នកស្រី អ៊ីង សៀក
លោក អ៊ុក ថៃស្រុន និងភរិយា
លោក តុប ចង និងភរិយា
លោក ហួត ឈាង និងភរិយា
លោក លី អៀមជូ និងភរិយា
លោក ប៉ែន យ៉េត និងភរិយា
លោក សែម សម្បត្តិ និងភរិយា
លោក សុខ យឿន និងភរិយា
លោក ហេង អ៊ីឡោ និងអ្នកស្រី ច័ន្ទ ហ៊ុយសាង
លោក យឹម ង៉េង និងភរិយា
លោក សរ ណួត និងភរិយា
លោក អ៊ុយ ហួត និងភរិយា

●●●

www.budinst.gov.kh www.elibraryofcambodia.org

# ប្រវត្តិ
# វត្តមុនីប្រសិទ្ធិវង្ស

វត្តមុនីប្រសិទ្ធិវង្ស ឋិតនៅក្នុងឃុំព្រែកព្នៅ ស្រុកពញាឮ ខេត្តកណ្ដាល ។ វត្តនេះមានផ្ទៃដីទំហំប្រមាណ ៣ ហិកតា តាំងនៅកណ្ដាលជលាស័យ ដែលមានព្រំខាងត្បូងជាប់នឹងថ្នល់ទៅភ្នំប្រសិទ្ធិ និង មានព្រំបីទិសទៀត ព័ទ្ធដោយទឹក ។

វត្តនេះ មានប្រវត្តិដូចតទៅនេះ ៖

វត្តមុនីប្រសិទ្ធិវង្សនេះ កាលដើមឡើយ គឺជាទីព្រៃ, ជាដីកម្មសិទ្ធិរបស់អ្នកស្រុកនៅឃុំព្រែកព្នៅ ។ ក្រោយពីមានសេចក្ដីស្នើសុំបង្កើតវត្តនៅទីកន្លែងនោះ ម្ចាស់ដីទាំងអស់ដែលសុទ្ធតែជាអ្នកមានសទ្ធាជ្រះថ្លាក្នុងព្រះពុទ្ធសាសនា ក៏បានប្រគេន និងជូនដីនេះទៅព្រះសង្ឃ និងគណៈកម្មការវត្ត ដើម្បីកសាងវត្តថ្មី នេះឡើង ។

មូលហេតុដំបូង ដែលនាំអោយប្រារព្ធកសាងវត្តមុនីប្រសិទ្ធិវង្សនេះឡើង គឺដោយសារពុទ្ធបរិស័ទនៅក្នុងឃុំព្រែកព្នៅ មានការលំបាកក្នុងការធ្វើបុណ្យទាន ដោយវត្តនៅក្នុងឃុំមានតែមួយ មិនអាចគ្រប់គ្រាន់តាមសេចក្ដីត្រូវការធ្វើបុណ្យទាន និង ការអប់រំបណ្ដុះបណ្ដាលបញ្ញាស្មារតី សីលធម៌របស់ពុទ្ធបរិស័ទបាន ទើបមានសេចស្នើសុំបង្កើតវត្តថ្មីនេះឡើង ដើម្បីទុកជាទីគោរពសក្ការះរបស់ពុទ្ធបរិស័ទ តរៀងទៅ ។

www.budinst.gov.kh www.elibraryofcambodia.org

គោលបំណងដ៏ល្អប្រពៃនេះ ត្រូវបានពុទ្ធបរិស័ទទាំងអស់គាំទ្រ រួចក៏ធ្វើចុតហ្មាយថ្វាយព្រះមហាក្សត្រ ដើម្បីសុំព្រះរាជទានព្រះរាជានុ-ញ្ញាតកសាងវត្ត ។ ចុតហ្មាយរបស់ពុទ្ធបរិស័ទ ត្រូវបានព្រះអង្គម្ចាស់ ស៊ីសុវត្ថិ មុនីជាតិ និងអ្នកម្នាង ឃុន គីមយ៉ុង ជួយឧបត្ថម្ភគាំទ្រ ដោយព្រះអង្គម្ចាស់បានជួយសម្រួលទំនាក់ទំនង គឺព្រះអង្គបានចូលគាល់ព្រះមហាក្សត្រ ដើម្បីទូលថ្វាយអំពីសំណូមពររបស់ប្រជារាស្ត្រដែលស្នើសុំបង្កើតវត្តថ្មីនេះ ។

ដោយទ្រង់បានជ្រាបសព្វគ្រប់ពីសំណូមពររបស់ពុទ្ធបរិស័ទ នៅឃុំព្រែកឈ្មៀរួចហើយ ទើបព្រះមហាក្សត្រិយានីស៊ីសុវត្ថិ មុនីវង្ស កុសមៈនារីរតន៍ សេរីវឌ្ឍនា ជាអម្ចាស់ជីវិតតំកល់លើត្បូងនៃយើង ព្រះអង្គបានឡាយព្រះហស្តលេខាព្រះរាជាអនុញ្ញាតអោយបង្កើតវត្តថ្មីនេះឡើង ព្រមទាំងប្រទាននាមវត្តនេះយ៉ាងពិរោះ និងសក្តិសមជាទីបំផុត ទៅនឹងស្ថាន-ភាពទីកដី ដោយព្រះមហាក្សត្រិយានី ជាអម្ចាស់នៃយើងទ្រង់យល់ថា ៖

ទី១. ទីកដីវត្តថ្មីនេះ មានទីតាំងស្ថិតនៅចំពីមុខភ្នំប្រសិទ្ធិ,

ទី២. វត្តដែលស្នើសុំបង្កើតថ្មីនេះ ត្រូវបានព្រះរាជវង្សនៃព្រះមហាក្សត្រជួយឧបត្ថម្ភផង ។ អាស្រ័យហេតុនោះ ទើបព្រះអង្គទ្រង់ប្រទាននាមវត្តនេះថា ៖ « **វត្ត មុនីប្រសិទ្ធិវង្ស** » ។

ក្រោយពីបានទទួលនូវព្រះរាជាអនុញ្ញាតពីព្រះមហាក្សត្ររួចមក,

www.budinst.gov.kh www.elibraryofcambodia.org

នៅថ្ងៃព្រហស្បតិ៍ ១៥ កើត ខែស្រាពណ៍ ឆ្នាំមមី ទោស័ក ព.ស ២៤៩៨ ត្រូវនឹងថ្ងៃទី២៧ ខែកញ្ញា ឆ្នាំ១៩៥៤ វត្តមុនីប្រសិទ្ធិវង្ស បានចាប់កំណើត កសាងឡើង ដោយពុទ្ធបរិស័ទបានប្រមូលគ្នា ទាំងក្មេង ចាស់ ប្រុស ស្រី យ៉ាងច្រើនកុះករ នាំគ្នាចាប់ផ្ដើមកាប់ឆ្ការព្រៃ និង លើកដីឡើងពង្រាប ធ្វើជាទីតាំងនៃវត្ត ។

ក្រោយពីបានរៀបចំទីវត្ត និងបានសាងសង់កុដិ ល្មមស្នាក់នៅសមរម្យហើយ ពុទ្ធបរិស័ទជើងវត្ត បានសុំនិមន្តព្រះតេជព្រះគុណ ព្រះនាម **ម៉ាន់ អ៊ុន** ដែលគង់នៅវត្តជោតមង្គល ឃុំព្រែកព្នៅ មកគង់ធ្វើជាចៅអធិការទី១ នៃវត្តមុនីប្រសិទ្ធិវង្សនេះ ។

ចាប់តាំងពីឆ្នាំ ១៩៥៤ ដល់ឆ្នាំ ១៩៥៦ ព្រះចៅអធិការ ម៉ាន់ អ៊ុន បានដឹកនាំពុទ្ធបរិស័ទលើកដីទីវត្តបន្តទៀតអោយបានទូលាយ ហើយបានកសាងកុដិ សាលា និងព្រះពន្លៃ ធ្វើអំពីឈើមួយចំនួនប៉ុណ្ណោះ ។ នៅឆ្នាំ ១៩៥៦ ព្រះអង្គចៅអធិការ ព្រះនាម ម៉ាន់ អ៊ុន ក៏លាចាកសិក្ខាបទទៅ ។

នៅថ្ងៃសៅរ៍ ៨ កើត ខែអាសាឍ ឆ្នាំវក ចត្វាស័ក ព.ស ២៥០០ ត្រូវនឹងថ្ងៃទី១៦ ខែកក្កដា គ.ស ១៩៥៦ ព្រះតេជព្រះគុណ ព្រះនាម **ម៉ាំង ឃួន** ត្រូវបានទទួលនាទីជាចៅអធិការទី២ សំរាប់វត្តមុនីប្រសិទ្ធិវង្ស ជាបន្ត ។

ពីឆ្នាំ១៩៥៦ ដល់ឆ្នាំ១៩៧៣ ព្រះចៅអធិការ ម៉ាំង ឃួន បានដឹកនាំពុទ្ធបរិស័ទកសាងនូវសមិទ្ធិថ្មី១ថែមទៀត ដូចជាបានកសាងកុដិមួយ

www.budinst.gov.kh www.elibraryofcambodia.org

ខ្នងធ្វើអំពីបេតុង, បានលើកទ្វល, រៀបខឿនជុំវិញព្រះពលៃ, កសាងព្រះពលៃ ធ្វើអំពីឈើ ប្រក់សង្កសី, បានកសាងសាលារៀនមួយខ្នងធ្វើពីបេតុង មាន ៣ បន្ទប់, បានកសាងឧបដ្ឋានសាលាធ្វើពីឈើ ប្រក់សង្កសី, និងបានកសាងកុដិតូច១ពីរ ធ្វើអំពីឈើ ប្រក់ស្លឹក ។

នៅថ្ងៃសៅរ៍ ទី ១៨ ខែមករា ឆ្នាំ ១៩៧៣ ព.ស ២៥១៦ ព្រះចៅអធិការទី២ ព្រះនាម ម៉ាំង យួន ក៏ទទួលអនិច្ចធម្មទៅ ។

ក្រោយពេលដែលព្រះចៅអធិការទី២ បានអនិច្ចធម្មទៅនោះ វត្តមុនីប្រសិទ្ធិវង្សនេះ ពុំទាន់មានការតែងតាំងចៅអធិការថ្មីបន្តទៀតទេ ដោយនៅឆ្នាំ ១៩៧៣ នោះ (ក្នុងរបបលោក លន់ នល់) ប្រទេសជាតិទាំងមូល ត្រូវធ្លាក់ក្នុងសង្គ្រាម អសន្តិសុខកាន់តែធ្ងន់ធ្ងរ ។ ថ្ងៃ ១៧ មេសា ១៩៧៥ ប្រទេសជាតិទាំងមូល ត្រូវផ្លាស់ប្តូររបបនយោបាយ, ទីវត្តមុនីប្រសិទ្ធិវង្ស ត្រូវបានបោះបង់ចោល ដោយរបបប៉ុលពត, អៀងសារី បានជម្លៀសទាំងព្រះសង្ឃ ទាំងប្រជារាស្ត្រ អោយចេញពីវត្តអារាម និងពីស្រុកភូមិ ទៅរស់នៅតំបន់ជនបទដាច់ស្រយាល ។

ពីឆ្នាំ១៩៧៥ ដល់ដើមឆ្នាំ១៩៧៩ ទីវត្តមុនីប្រសិទ្ធិវង្សទាំងមូល ត្រូវបានក្លាយទៅជាទីព្រៃរហោស្ថាន គួរអោយខ្លាច ។ សមិទ្ធផលនៅក្នុងវត្ត ដែលព្រះសង្ឃ និងពុទ្ធបរិស័ទបានខំប្រឹងប្រែងកសាងទាំងប៉ុន្មានដូចពោលខាងលើ ត្រូវបានរបបប្រល័យពូជសាសន៍ ប៉ុលពត, អៀងសារី កំទេចចោលទាំងស្រុង ពុំមានសេសសល់បន្តិចណាឡើយ ។ បន្ថែមពី

www.budinst.gov.kh www.elibraryofcambodia.org

លើនេះទៀត ពួកគេបានយកទីវត្តនេះ ប្រើជាកន្លែងដើម្បីចូកកកាយយកដីចេញ ទៅបំពេញកន្លែងផ្សេង ធ្វើអោយទីវត្តទាំងមូល ត្រូវក្លាយទៅជារណ្តៅ ជារណ្តូង ក្រហេងក្រហូងពាសសពេញទាំងអស់ ។

ពីឆ្នាំ១៩៧៩ ដល់ឆ្នាំ១៩៩០ មុនពេលស៊ុបង្កើតវត្តនេះជាថ្មីឡើងវិញ ទីវត្តនេះទាំងមូលក៏នៅតែជាព្រៃជុំជិតដដែល ប្រជារាស្ត្របានប្រើទីនេះ ជាកន្លែងដាំដំណាំ ជាស្រះចិញ្ចឹមត្រី ជាទីសត្តឃាដបណ្តោះអាសន្ន ។ ប៉ុន្តែក្រោយមក នៅដើមឆ្នាំ ១៩៩០, ដោយមានការបើកទូលាយក្នុងការប្រតិបត្តិ និងជំនឿសាសនារបស់រដ្ឋាភិបាល (អតីតរដ្ឋកម្ពុជា) ផងនោះ ទើបនៅថ្ងៃអង្គារ ទី២៤ ខែមេសា ឆ្នាំ ១៩៩០ មានពួកពុទ្ធបរិស័ទជាច្រើន ដែលជាអ្នកជឿជាក់ និងគោរពព្រះពុទ្ធសាសនា បានមូលមតិឯកភាពគ្នាស្នើសុំអាជ្ញាធរឃុំ - ស្រុក - ខេត្ត យកទីវត្តចាស់នេះ ដើម្បីរៀបចំស្ថាបនា និងកសាងវត្តជាថ្មីឡើងវិញ ។ គោលបំណងនៃការស្នើសុំនេះ គឺអាស្រ័យដោយហេតុពីរយ៉ាង គឺ :

- ទីមួយ : ដោយកន្លែងនេះ ជាទីវត្តចាស់ពីដើមមក ពុំគួរទុកចោលជាទីព្រៃទំនេរ ឥតប្រយោជន៍ឡើយ ។
- ទីពីរ : ដោយពុទ្ធបរិស័ទជ្រះថ្លាចំពោះព្រះភិក្ខុ មួង រ៉ា ដែលគង់នៅវត្តជោតមង្គល (ហៅវត្តព្រៃកញ្ចៅ), លោកមានលក្ខណសម្បត្តិគួរជាទីស្រឡាញ់ ហើយប្រតិបត្តិត្រឹមត្រូវ ម៉ឺតចត់ក្នុងធម៌វិន័យពុទ្ធសាសនា និងជាភិក្ខុមួយអង្គ ដែលមានទឹកព្រះទ័យជ្រះថ្លា ក្នុងការកសាងជាតិមាតុ-

www.budinst.gov.kh www.elibraryofcambodia.org

ភូមិផង ។

ដោយមូលហេតុទាំងពីរខាងលើ និងដោយយោលតាមសេចក្តីស្នើសុំពីពុទ្ធបរិស័ទ, អាជ្ញាធរឃុំ - ស្រុក បានអនុញ្ញាតផ្តល់ជូន តាមសំណូមពរស្នើសុំ ។

នៅថ្ងៃពុធ ទី២៥ ខែមេសា ឆ្នាំ ១៩៩០ ពុទ្ធបរិស័ទបានសូមនិមន្តព្រះភិក្ខុ **ម្ជូង វ៉ា** មកគង់នៅជាចៅអធិការ នៅទីវត្តមុនីប្រសិទ្ធិវង្សនេះ ដោយបានធ្វើពិធីដង្ហែទាំងព្រះ **ពុទ្ធរូប** ទាំងព្រះភិក្ខុ **ម្ជូង វ៉ា** រមណីយត្ថេរ តាមពិធីព្រះពុទ្ធសាសនា យ៉ាងអធិកអធមបំផុត ។

ក្នុងរយៈពេល ៥ ឆ្នាំ ៨ ខែ ៧ ថ្ងៃ នៃសកម្មភាពបំរើប្រទេសជាតិ និងសាសនា របស់ព្រះចៅអធិការ ម្ជូង វ៉ា (រមណីយត្ថេរ) (គិតពីថ្ងៃពុធ ទី២៥ ខែមេសា ឆ្នាំ ១៩៩០ ត្រូវនឹងថ្ងៃ ១ កើត ខែពិសាខ ឆ្នាំមមី ទោស័ក ព.ស ២៥៣៤ រហូតដល់ថ្ងៃបញ្ចុះខ័ណ្ឌសីមា គឺថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ត្រូវនឹងថ្ងៃ ៨ កើត ខែមាឃ ឆ្នាំច ឆស័ក ព.ស ២៥៣៨ នេះ មានរយៈពេល ៥ ឆ្នាំ ៨ ខែ ៧ ថ្ងៃ) ទីវត្តមុនីប្រសិទ្ធិវង្សទាំងមូល ត្រូវបានកសាងជាថ្មីឡើងវិញទាំងអស់ ។ ជាការជាក់ស្តែងនៃការកសាងក្នុងរយៈពេលខាងលើ បានធ្វើអោយសំរេចនូវសមិទ្ធផល និងបានចំណាយទឹកប្រាក់ មានដូចខាងក្រោម ៖

១. ចាក់ដីបំពេញស្រះ អណ្តូងក្នុងទីវត្តទាំងមូល ជាបណ្តើរៗ រហូតស្ទើរពាសពេញទីវត្ត ។ ការចាក់ដីនេះ ត្រូវចំណាយអស់ប្រាក់ជារួម

www.budinst.gov.kh www.elibraryofcambodia.org

ពីររយម្ភៃប្រាំលានរៀល (២២៥.០០០.០០០៖០០) ស្មើនឹងប្រាំបួនម៉ឺនដុល្លារអាមេរិក (90,000 USD) ។

២. នៅថ្ងៃសៅរ៍ ទី២៧ ខែកក្កដា ឆ្នាំ១៩៩០ បានចាប់ផ្ដើមសាងសង់ឧបដ្ឋានសាលាមួយខ្នង ធ្វើពីស៊ីម៉ង់ ប្រក់ក្បឿង, បណ្ដោយប្រវែង ២២ ម៉ែត្រ ទទឹង ១៥ ម៉ែត្រ ហើយត្រូវចំណាយបច្ច័យអស់ ម្ភៃបួនលានបីសែនរៀល (២៤.៣០០.០០០៖០០) ស្មើនឹងប្រាំបួនពាន់ ប្រាំពីររយម្ភៃដុល្លារអាមេរិក (9,720 USD) ។

៣. នៅថ្ងៃព្រហស្បតិ៍ ទី១០ ខែឧសភា ឆ្នាំ ១៩៩០ បានបន្តកសាងវច្ចកុដិ (បង្គន់) មួយ ធ្វើពីស៊ីម៉ង់ ប្រក់ក្បឿង មាន ៤ បន្ទប់ បណ្ដោយ ៦ ម៉ែត្រ ទទឹង ៣ ម៉ែត្រ ត្រូវចំណាយអស់បច្ច័យ មួយលានបីសែនរៀល (១.៣០០.០០០៖០០) ស្មើនឹងប្រាំរយម្ភៃដុល្លារអាមេរិក (520 USD) ។

៤. នៅថ្ងៃសៅរ៍ ទី៩ ខែកុម្ភៈ ឆ្នាំ ១៩៩១ បានផ្ដើមកសាងសាលាពុទ្ធិកបឋមសិក្សាមួយខ្នង ធ្វើពីស៊ីម៉ង់ ប្រក់ក្បឿង បណ្ដោយប្រវែង ២៥ ម៉ែត្រ ទទឹង ៩ ម៉ែត្រ ចែកចេញជា ៣ បន្ទប់ ហើយត្រូវចំណាយអស់បច្ច័យចំនួន ប្រាំពីរលាន បីសែនរៀល (៧.៣០០.០០០៖០០) ។

៥. នៅថ្ងៃអាទិត្យ ទី១០ ខែមីនា ឆ្នាំ ១៩៩១ បានចាប់ផ្ដើមកសាងរបងនៅប៉ែកខាងត្បូងវត្ត ធ្វើពីស៊ីម៉ង់ ត្រូវចំណាយបច្ច័យអស់ចំនួន ដប់បួនលាន ពីរសែនរៀល (១៤.២០០.០០០៖០០) ។

www.budinst.gov.kh www.elibraryofcambodia.org

៦. នៅថ្ងៃអាទិត្យ ទី២៤ ខែមីនា ឆ្នាំ១៩៩១ បានផ្តើមកសាងក្លោងទ្វារមួយ ធ្វើពីស៊ីម៉ង់ រំលេចដោយក្បូរក្បាច់បូរាណ មានបណ្តោយ ៨,៥០ ម៉ែត្រ ទទឹងជើងក្រោមនីមួយៗ ១,៨០ ម៉ែត្រ កំពស់ ១១ ម៉ែត្រ ហើយត្រូវចំណាយអស់បច្ច័យចំនួន ប្រាំបីលាន ប្រាំបួនសែនរៀល (៨.៩០០.០០០៛០០) ស្មើនឹង បីពាន់ ប្រាំរយ ហុកហិបដុល្លារអាមេរិក (3,560 USD) (ចំពោះក្លោងទ្វារនេះ នៅថ្ងៃសៅរ៍ ទី៧ ខែមករា ឆ្នាំ ១៩៩៥ ត្រូវបានជួសជុលកែលំអឡើងវិញ ស្ទើរទាំងអស់) ។

៧. នៅថ្ងៃអាទិត្យ ទី១៣ ខែតុលា ឆ្នាំ១៩៩១ បានកសាងទូកមួងផ្នែកបុរសមួយ មានឈ្មោះថា «**ពេជ្រមុនី**» មានបណ្តោយ ២០ ម៉ែត្រ មាន ១៥ ខ្ទង់ និងចំណុះកីឡាករចែវចំនួន ២៧ នាក់ ហើយត្រូវចំណាយបច្ច័យអស់ចំនួន ពីរលាន មួយសែនរៀល (២.១០០.០០០៛០០) ស្មើនឹង ប្រាំបីរយ សែសិបដុល្លារអាមេរិក (840 USD) ។

៨. នៅថ្ងៃសៅរ៍ ទី៦ ខែកុម្ភៈ ឆ្នាំ ១៩៩៣ ត្រូវនឹងថ្ងៃ ១៥ កើត ខែមាឃ ឆ្នាំវក ចត្វាស័ក ព.ស ២៥៣៦ បានធ្វើពិធីបញ្ចុះបឋមសិលា ជានិមិត្តរូបនៃកិច្ចចាប់ផ្តើមកសាងព្រះវិហារធំ ។

ថ្ងៃពុធ ទី២១ ខែមេសា ឆ្នាំ ១៩៩៣ ត្រូវនឹងថ្ងៃ ១ កើត ខែពិសាខ ឆ្នាំរកា បញ្ចស័ក ព.ស ២៥៣៧ បានចាប់ផ្តើមកសាងព្រះវិហារធំ មានពីរជាន់ បណ្តោយ ៣២ម៉ែត្រ ទទឹង ១៨ម៉ែត្រ កំពស់ពីផ្ទៃដី រហូតដល់ត្រីសូល៍ ប្រវែង ៤៣ ម៉ែត្រ រំលេចដោយក្បូរក្បាច់បូរាណគ្រប់

www.budinst.gov.kh www.elibraryofcambodia.org

យ៉ាង ស្អើរពាសពេញក្នុងវិហារ ។

៩. ទន្ទឹមនឹងពេលកំពុងកសាងព្រះវិហារ, នៅថ្ងៃពុធ ទី៦ ខែកក្កដា ឆ្នាំ ១៩៩៤ ត្រូវនឹងថ្ងៃ ១៣ រោច ខែជេស្ឋ ឆ្នាំច ឆស័ក ព.ស ២៥៣៨ បានចាប់ផ្តើមកសាងកុដិព្រះចៅអធិការវត្តមួយខ្នងថែមទៀត ដែលធ្វើពីបេតុង មានពីរជាន់ បណ្តោយ ២៦ ម៉ែត្រ ទទឹង ១១ ម៉ែត្រ ។ ការកសាងព្រះវិហារ និងកុដិ ត្រូវធ្វើឡើងស្របពេលជាមួយគ្នា រហូតមកដល់ថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ ១៩៩៥, ព្រះវិហារ និងកុដិចៅអធិ. ការ ត្រូវហើយស្រេចជាស្ថាពរ ក្នុងពេលជាមួយគ្នាដែរ ។

• ចំពោះកុដិ ត្រូវចំណាយអស់បច្ច័យចំនួន ចិតសិបពីរលាន ប្រាំបីសែនរៀល (៧២.៨០០.០០០៛០០) ស្មើនឹងពីរម៉ឺន ប្រាំបីពាន់ដុល្លារអាមេរិក (28,000 USD) ។

• ចំពោះព្រះវិហារ ត្រូវចំណាយអស់បច្ច័យចំនួន ប្រាំបួនរយសែសិបប្រាំលានរៀល (៩៤៥.០០០.០០០៛០០) ស្មើនឹងបីរយ ចិតសិបប្រាំបីពាន់ដុល្លារអាមេរិក (378,000 USD) (ដោយពុំបានគិតតម្លៃទ្វារព្រះវិហារ ទាំងលើ ទាំងក្រោម ចំនួន ១៨ ទ្វារថែមទៀតផងទេ) ។

•ប្រាក់ចំណាយសរុប ចាប់តាំងពីពេលផ្តើមការកសាង រហូតដល់ពេលបញ្ចុះខ័ណ្ឌសីមានេះ មានចំនួន មួយពាន់ បីរយលាន ប្រាំបួនសែនរៀល (១.៣០០.៩០០.០០០៛០០) ស្មើនឹងបួនរយ កៅសិបបួនពាន់ដុល្លារអាមេរិក (494,080 USD) ។ រីឯព្រះវិហារនេះ ត្រូវប្រើពេល

www.budinst.gov.kh www.elibraryofcambodia.org

កសាងចំនួនតែ ២ ឆ្នាំ ១០ ខែតែប៉ុណ្ណោះ ។

ក្រោយពីបានកសាងព្រះវិហារដ៏ល្អប្រណីតនេះរួចស្រេចជាស្ថា-ពរមក ព្រះចៅអធិការ គណៈកម្មការ អាចារ្យវត្ត ព្រមទាំងពុទ្ធបរិស័ទជើងវត្តមុនីប្រសិទ្ធិវង្ស ដែលនៅក្នុងឃុំព្រែកព្នៅ និងនៅរាជធានីភ្នំពេញ បានមូលមតិគ្នាជាឯកច្ឆ័ន្ទ ប្រារព្ធធ្វើពិធីបុណ្យបញ្ចុះខ័ណ្ឌសីមា តាមពុទ្ធ-ប្បញ្ញ ត្តិ និងពុទ្ធានុញ្ញ ាត ព្រមទាំងតាមទំនៀមទម្លាប់នៃព្រះពុទ្ធសាសនា មានរយះពេលបីយប់ បួនថ្ងៃ គឺចាប់ពីថ្ងៃព្រហស្បតិ៍ ទី២៣ ខែកុម្ភៈ ឆ្នាំ ១៩៩៥ ត្រូវនឹងថ្ងៃ ៨ រោច ខែមាឃ ឆ្នាំច ឆស័ក ព.ស ២៥៣៨ រហូតដល់ថ្ងៃអាទិត្យ ទី ២៦ ខែកុម្ភៈ ឆ្នាំ១៩៩៥ ត្រូវនឹងថ្ងៃ ១១ រោច ខែមាឃ ឆ្នាំច ឆស័ក ព.ស ២៥៣៨ ទើបធ្វើពិធីឆ្លងជាកិច្ចបង្ហើយបុណ្យ ។

ក្នុងពិធីដ៏មហាឡារិកនេះ, នៅថ្ងៃទី ២៤ ខែ កុម្ភៈ ឆ្នាំ ១៩៩៥ ព្រះករុណាព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា និងសម្តេចព្រះមហេសី ព្រះអគ្គពុទ្ធសាសនូ-បត្ថម្ភក៏ ទ្រង់ស្តេចយាងជាព្រះរាជាធិបតី ក្នុងពិធីសម្ពោធកាត់ខ្សែគ្រឹះសីមាព្រះវិហារថ្មី នៃវត្តមុនីប្រសិទ្ធិវង្សនេះ ផងដែរ ។

* * *

www.budinst.gov.kh www.elibraryofcambodia.org

# បសំសនីយបណ្ណ
## ចំពោះស្នាព្រះហស្ត
## ព្រះចៅអធិការវត្ត មុនីប្រសិទ្ធិវង្ស

ព្រះរមណីយត្ថេរោ **មួង រ៉ា** ព្រះចៅអធិការវត្តមុនីប្រសិទ្ធិវង្ស បានយកព្រះទ័យទុកដាក់ និងជាប់ជំពាក់ជួយកសាង ស្ទើរតែគ្រប់កិច្ចការសង្គមជាតិ និងកិច្ចការព្រះពុទ្ធសាសនា ។ ដោយហេតុនេះ ទើបព្រះអង្គបានទទួលនូវការគោរពកោតសរសើរពីអាជ្ញាធរស្រុក-ខេត្ត និងរដ្ឋាភិបាលអតីតរដ្ឋកម្ពុជា ជាបន្តបន្ទាប់ ដូចតទៅ ៖

១- ឆ្នាំ ១៩៨៧ ព្រះអង្គបានទទួលប័ណ្ណសរសើរពីអភិបាលខេត្តកណ្តាល ចំពោះស្នាព្រះហស្តកសាងសំណង់នៅក្នុងឃុំព្រែកឡៅ ។

២- ឆ្នាំ ១៩៨៨ ព្រះអង្គបានទទួលប័ណ្ណសរសើរពីអភិបាលខេត្តកណ្តាល ម្តងទៀត ចំពោះស្នាព្រះហស្តកសាងផ្លូវ សាលារៀន និងសំណង់ក្នុងឃុំព្រែកឡៅ ។

៣- ឆ្នាំ ១៩៨៩ ព្រះអង្គបានទទួលប័ណ្ណកសាងជាតិពីក្រុមប្រឹក្សារដ្ឋមន្ត្រី ចំពោះស្នាព្រះហស្តកសាងផ្លូវ សាលារៀន នៅឃុំព្រែកឡៅ ។

៤- ឆ្នាំ ១៩៨៩ ព្រះអង្គបានទទួលប័ណ្ណសរសើរពីក្រុមប្រឹក្សារដ្ឋមន្ត្រី ចំពោះស្នាព្រះហស្តជួយកសាងវិស័យផ្សេងៗ រយៈពេល ៩ ឆ្នាំ (១៩៧៩ - ១៩៨៦) ។

www.budinst.gov.kh www.elibraryofcambodia.org

៥. ឆ្នាំ ១៩៩១ ព្រះអង្គបានទទួលប័ណ្ណសរសើរពីក្រុមប្រឹក្សារដ្ឋមន្ត្រីម្តងទៀត ចំពោះស្នាព្រះហស្ត បានជួយរួមចំណែកក្នុងការកសាងប្រទេសជាតិ ។

***

## សមណស័ក្តិ

សមណស័ក្តិ ដែលព្រះរមណីយត្ថេរោ **មួង រ៉ា** ព្រះចៅអធិការវត្តមុនីប្រសិទ្ធិវង្ស បានទទួលចាប់តាំងពីបានឧបសម្បទជាភិក្ខុភាវៈ អស់រយៈពេល ១៦ ព្រះវស្សាក្នុងព្រះពុទ្ធសាសនា ជាលំដាប់រៀងមក គឺ ៈ

១. នៅថ្ងៃសុក្រ ទី២៥ ខែឧសភា គ.ស ១៩៩០ ត្រូវនឹងថ្ងៃ ១ កើត ខែជេស្ឋ ឆ្នាំមមី ទោស័ក ព.ស ២៥៣៤ ព្រះអង្គបានទទួលនាទីជាប្រធានដឹកនាំ និងគ្រប់គ្រងវត្តមុនីប្រសិទ្ធិវង្ស ក្នុងព្រះវស្សាទី១២ ។

២. នៅថ្ងៃព្រហស្បតិ៍ ទី៧ ខែវិច្ឆិកា គ.ស ១៩៩១ ត្រូវនឹងថ្ងៃ ១ កើត ខែកត្តិក ឆ្នាំមមែ ត្រីស័ក ព.ស ២៥៣៥ ព្រះអង្គបានទទួលតែងតាំងជាព្រះចៅអធិការវត្តមុនីប្រសិទ្ធិវង្ស ក្នុងព្រះវស្សាទី១៣ ។

៣. នៅថ្ងៃសុក្រ ទី១៨ ខែកុម្ភៈ ឆ្នាំ ១៩៩៤ ត្រូវនឹងថ្ងៃ ៨ កើត ខែមាឃ ឆ្នាំរកា បញ្ចស័ក ព.ស ២៥៣៧ ព្រះរមណីយត្ថេរោ មួង រ៉ា បានទទួលពីសម្តេចព្រះមហាសុមេធាធិបតី **ទេព វង្ស** ព្រះសង្ឃរាជគណៈមហានិកាយ នូវសញ្ញាប័ត្រតែងតាំងជាសមុហ៍អនុគណ ស្រុកពញាឮ

www.budinst.gov.kh www.elibraryofcambodia.org

ខេត្តកណ្តាល ក្នុងព្រះវស្សាទី១៦ ។

***

# សេចក្តីចម្លង

## បឋមសិលា នៃឧបោសថាគារ

ដែលផ្តើមបញ្ចុះនៅថ្ងៃសៅរ៍ ទី ៦ ខែកុម្ភៈ ឆ្នាំ ១៩៩៣

ត្រូវនឹងថ្ងៃ ១៥ កើត ខែមាឃ ឆ្នាំរកា ចត្វាស័ក ព.ស. ២៥៣៦ ។

**ចិរំ តិដ្ឋតុ ពុទ្ធសាសនំ**

ពុទ្ធបរិស័ទទាំងអស់ រួមគ្នាប្រារព្ធកសាងព្រះពុទ្ធសាសនា ក្រោមការដឹកនាំរបស់ព្រះគ្រូរមណីយត្ថេរោ **មួង វ៉ា** ព្រះចៅអធិការវត្តមុនីប្រសិទ្ធិវង្ស និងជាព្រះសមុហ៍អនុគណស្រុកពញាឮ ខេត្តកណ្តាល ។

ក្នុងសម័យកាល ៖

- សម្តេចព្រះមហាសុមេធាធិបតី **ទេព វង្ស** ព្រះសង្ឃ-រាជ គណៈមហានិកាយ ។

- ព្រះវិមលវេទី **ឡុង យុង** មេគណ ខេត្តកណ្តាល ។

- ព្រះបញ្ញាទីបោ **ម៉ា ជឹម** អនុគណ ស្រុកពញាឮ ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះសង្ឃដែលគង់ចាំព្រះវស្សា ក្នុងវត្តមុនីប្រសិទ្ធិវង្ស មាន ៤ អង្គគឺ ៖

១. ព្រះសោភណត្ថេរ **ឡេង សុភី** ជាគ្រូសូត្រស្តាំ,

២. ព្រះតុសិតត្ថេរ **គោ កួច** ជាគ្រូសូត្រឆ្វេង,

៣. ភិក្ខុ **អែល សំណាង,** និង

៤. សាមណេរ **សន ឬទ្ធុស** ។

អាចារ្យវត្ត

. លោក អាចារ្យ **យូ ហួត**

. លោកអាចារ្យ **ខែក ថួន**

គណៈកម្មការវត្ត

. លោក **គេង ហ៊ី** ជាប្រធាន

. លោក **អ៊ួន សៀ** ជាអនុប្រធាន

មេជាងសំណង់ និងរចនាក្បូរក្បាច់ ដោយ

ស្ថាបនិក **ប៊ូ ចាន់ថាច**

ក្នុងសម័យកាលព្រះរាជាណាចក្រកម្ពុជា

ក្នុងរាជ្យព្រះបាទសម្តេចព្រះនរោត្តម **សីហនុ វរ្ម័ន** ជាព្រះមហាក្សត្រ នៃព្រះរាជាណាចក្រកម្ពុជា និង សម្តេចព្រះមហេសី **មុនីនាថ សីហនុ** ។

www.budinst.gov.kh www.elibraryofcambodia.org

ព្រះរាជរដ្ឋាភិបាល ដឹកនាំដោយ ៖

- សម្តេចក្រុមព្រះ **នរោត្តម រណឫទ្ធិ** នាយករដ្ឋមន្ត្រីទី១,
- សម្តេច **ហ៊ុន សែន** នាយករដ្ឋមន្ត្រីទី២,
- អភិបាលខេត្តកណ្តាល ឯកឧត្តម **ចក់ សារិក**,
- អភិបាលស្រុកពញាឮ លោក **ពេញ សឿន**,
- មេឃុំព្រែកតាមៅ លោក **ពេជ ណាំ** ។

ថ្ងៃ ១៥ កើត ខែបុស្ស ឆ្នាំច ឆស័ក ព.ស ២៥៣៨

ត្រូវនឹងថ្ងៃទី ១៦ ខែមករា គ.ស ១៩៩៥

**ជា សុខែម**

អ្នករៀបរៀង

www.budinst.gov.kh www.elibraryofcambodia.org

www.budinst.gov.kh www.elibraryofcambodia.org